ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៤១/២១ ក.ប/ស.ជ.ណ.រ.ប.ប

# សេចក្តីជូនដំណឹង
## ស្តីពី
## កាលបរិច្ឆេទ និងមណ្ឌលប្រឡងជ្រើសរើស
## ក្របខណ្ឌថ្មីឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សិស្ស-និស្សិត បុគ្គលិកក្រុមហ៊ុន អង្គការ និងមន្ត្រីរាជការទាំងពីរភេទដែលបានដាក់ពាក្យប្រឡងប្រជែងជ្រើសរើសក្របខណ្ឌសម្រាប់ឆ្នាំ២០២១ ដើម្បីចូលបម្រើការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈសេចក្តីជូនដំណឹងលេខ ០០៤/២១ ក.ប/ស.ជ.ណ.រ.ប.ប ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ និងសេចក្តីជូនដំណឹងលេខ ០២១/២១ ក.ប/ស.ជ.ណ.រ.ប.ប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ ឱ្យបានជ្រាបថា កាលបរិច្ឆេទប្រឡងនឹងប្រព្រឹត្តទៅនៅ***ថ្ងៃសុក្រ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២១*** នៅមណ្ឌល ***"វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ"*** ស្ថិតនៅតាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី ជាប់នឹងរបងវត្តទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

***សូមបញ្ជាក់ជូនបេក្ខជនផងដែរថា៖***

- បញ្ជីឈ្មោះបេក្ខជននឹងបិទផ្សាយនៅថ្ងៃព្រហស្បតិ៍ ទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានបិទនៅមណ្ឌលប្រឡង (វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ) និងនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វេលាម៉ោង ១០:០០ព្រឹក
- បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីត្រូវមកដល់បន្ទប់ប្រឡងនៅថ្ងៃសុក្រ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ យ៉ាងយូរត្រឹមម៉ោង ៦:០០ព្រឹក ក្នុងករណីបេក្ខជនដែលមកដល់មណ្ឌលប្រឡង យឺត១៥នាទី ក្រោយពីចែកវិញ្ញាសាប្រឡងមិនត្រូវបានអនុញ្ញាតឱ្យចូលប្រឡងឡើយ
- ត្រូវភ្ជាប់មកជាមួយនូវសលាកប័ត្រងកត្តជន កាតចាក់វ៉ាក់សាំងឬលិខិតបញ្ជាក់បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ចំនួនពីរដងរួចរាល់ និងត្រូវពាក់ម៉ាសជាប្រចាំ
- ករណីបេក្ខជនដែលខកខានមិនបានគោរពទៅតាមការកំណត់ខាងលើ គណៈកម្មការប្រឡងក្របខណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទទួលខុសត្រូវលើការបាត់បង់បេក្ខភាពប្រឡងឡើយ។

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងអស់អនុវត្ត និងជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១១រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០២១
រដ្ឋមន្ត្រី

អ៊ិត សំហេង